# ព្រះជាម្ចាស់ដ៏គួរ
# អោយកោតស្ញប់ស្ញែង

PRAYER, FASTING
& CONSECRATION
JANUARY 11–15, 2021

EVERY NATION

© 2021 by Every Nation Churches & Ministries. All rights reserved.

Scripture quotations, unless otherwise noted, are from The Holy Bible,
English Standard Version (ESV) Copyright 2001 by Crossway,
a publishing ministry of Good News Publishers.

EveryNation.org/Fasting #ENfast2021

# មាតិកា


ការរៀបចំខ្លួនដើម្បីតមអាហារ.....2

ផែនការរបស់ខ្ញុំ.....5

សេចក្ដីផ្ដើម: ព្រះជាម្ចាស់ គឺអស្ចារ្យ និងល្អ.....13

ថ្ងៃទី១: ព្រះជាម្ចាស់អស្ចារ្យលើសអ្វីៗទាំងអស់.....17

ថ្ងៃទី២: ព្រះជាម្ចាស់មិនប្រួលប្រែ.....21

ថ្ងៃទី៣: ព្រះជាម្ចាស់សោយរាជ្យជាអធិបតេយ្យភាព.....25

ថ្ងៃទី៤: ព្រះជាម្ចាស់យុត្តិធម៌.....29

ថ្ងៃទី៥: ព្រះជាម្ចាស់មានព្រះហឫទ័យអត់ធ្មត់.....33

ថ្ងៃទី៦: ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរស.....37

# ការរៀបចំខ្លួនដើម្បីតមអាហារ

ហេតុអ្វីតមអាហារ?

ការតមអាហារ គឺជាឧបករណ៍ខាងវិញ្ញាណដែលព្រះជាម្ចាស់ប្រើប្រាស់ដើម្បីជម្រុញព្រះរាជ្យរបស់ព្រះអង្គ ផ្លាស់ប្តូរវាសនារបស់ប្រជាជាតិនានា ជំរុញឲ្យមានការផុសផុលខាងវិញ្ញាណ និងនាំយកជ័យជំនះដាក់ក្នុងជីវិតមនុស្សទាំងអស់។ ក្រុមជំនុំគ្រប់ជាតិសាសន៍ និងព័ន្ធកិច្ចតាមសាលា ធ្វើការអធិស្ឋាននេះចាប់ផ្តើមរៀងរាល់ដើមឆ្នាំថ្មី ដោយមានរយៈពេល៥ថ្ងៃនៃការអធិស្ឋាននិងតមអាហារ ដើម្បីបន្ទាបខ្លួនរបស់យើងចំពោះព្រះជាម្ចាស់, ថ្វាយខ្លួនយើងទៅកាន់ព្រះជាម្ចាស់សម្រាប់ឆ្នាំខាងមុខនេះ ហើយសហការគ្នាដើម្បីទទួលបានភាពទម្លុះទម្លាយ។

ព្រះយេស៊ូបានតមអាហារ!

***ពេលនោះ ព្រះវិញ្ញាណនាំព្រះយេស៊ូទៅវាលរហោស្ថាន អោយមារសាតាំងល្បួង បន្ទាប់ពីបានតមអាហារអស់រយៈពេលសែសិបថ្ងៃ សែសិបយប់មក ព្រះអង្គក៏ឃ្លាន។ (ម៉ាថាយ៤:១-២)***

***ព្រះយេស៊ូយាងត្រលប់ទៅស្រុកកាលីឡេវិញ ប្រកបដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ព្រះនាមរបស់ព្រះអង្គលឺល្បីល្បាញពាសពេញតំបន់នោះ។ (លូកា ៤:១៤)***

ព្រះយេស៊ូជ្រាបថា ព្រះអង្គត្រូវការកម្លាំងខាងវិញ្ញាណ ដើម្បីអាចបំពេញតាមព្រះហឫទ័យរបស់ព្រះបិតាបាន។ ការតមអាហារធ្វើឲ្យយើងខ្លាំងខាងឯវិញ្ញាណ និងធ្វើឲ្យយើងត្រៀមខ្លួនបានរួចជាស្រេចក្នុងការបំពេញភារកិច្ចដែលព្រះជាម្ចាស់ប្រទានឲ្យយើងធ្វើ។

ការតមអាហារគឺជាសកម្មភាពបន្ទាបខ្លួន និងញែកខ្លួនឲ្យបានវិសុទ្ធ

***នៅក្បែរព្រែកអាហាវ៉ានោះ ខ្ញុំបានប្រកាស់អោយធ្វើពិធីតមអាហារ ដើម្បីដាក់ខ្លួននៅចំពោះព្រះភ័ក្ត្រនៃព្រះរបស់យើង សូមព្រះអង្គប្រទានអោយយើង និងកូនចៅរបស់យើង ធ្វើដំណើរប្រកបដោយសុខសាន្ត ហើយអោយទ្រព្យសម្បត្តិរបស់យើងបានគង់វង្សផង*** *(អែសរ៉ា ៨:២១)*

---

ការបន្ទាបខ្លួនតាមរយៈការតមអាហារ និងអធិស្ឋានធ្វើអោយយើងទទួលបាននូវព្រះគុណរបស់ព្រះជាម្ចាស់ និងមានផ្លូវចូលទៅកាន់ដួងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ការតមអាហារធ្វើឲ្យយើងបានស្និទ្ធស្នាល និងងាយស្តាប់លឺព្រះសូរសៀងព្រះជាម្ចាស់

***នៅពេលដែលអ្នកទាំងនោះកំពុងតែធ្វើពិធីថ្វាយបង្គំព្រះអម្ចាស់ និងតមអាហារ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា៖ «ចូរញែកបារណាបាស និងសូលចេញដោយឡែក ដ្បិតយើងបានហៅអ្នកទាំងពីរមក អោយបំពេញកិច្ចការដែលយើងនឹងដាក់អោយធ្វើ»។ (កិច្ចការ១៣:២)***

ពេលយើងច្រានចោលការស្រេកឃ្លាន និងភាពរំខានពីលោកិយ៍ យើងអាចស្តាប់លឺព្រះសូរសៀងរបស់ព្រះជាម្ចាស់បានច្បាស់ជាងមុន។ យើងនឹងអាចផ្តោតទៅលើទ្រង់ និងចុះចូលទៅនឹងផែនការបស់ទ្រង់ បានទាំងស្រុង។

---

ការតមអាហារនាំអោយមានការផ្លាស់ប្រែជាថ្មី និងរួសរានឡើងវិញ

***ប្រសិនបើប្រជារាស្ត្ររបស់យើង គឺប្រជារាស្ត្រដែលជាកម្មសិទ្ធរបស់យើងផ្ទាល់ នាំគ្នាបន្ទាបខ្លួនអធិស្ឋាន និងស្វែងរកយើង ហើយប្រសិនបើគេបោះបង់ផ្លូវអាក្រក់របស់ខ្លួន យើងនឹងស្តាប់គេពីស្ថានបរមសុខ យើងនឹងលើកលែងទោសអោយគេរួចពីបាប ព្រមទាំងប្រោសស្រុកគេអោយបានជាផង (២របាក្សត្រ៧:១៤)***

ក្នុងប្រវត្តិសាស្ត្រ យើងឃើញថាព្រះជាម្ចាស់តែងតែឆ្លើយតបនឹងសំណូមអធិស្ឋាន និងការតមអាហារ ដោយព្រះអង្គរំដោះគេចេញពីគ្រោះមហន្តរាយ និងអោយប្រជាជាតិរបស់គេរស់រានឡើងវិញ។ ការតមអាហារជំរុញឲ្យយើងអធិស្ឋាន និងទូលអង្វរព្រះជាម្ចាស់សំរាប់អ្នកឯទៀតៗបានប្រសើរជាងមុន។

**ការតមអាហារធ្វើអោយមានសុខភាពល្អ**

ការតមអាហារជួយសម្អាតប្រព័ន្ធរំលាយអាហាររបស់យើង។ វេជ្ជបណ្ឌិតបានអះអាងថា ការតមអាហារជួយព្យាបាលជំងឺមួយចំនួនបាន។ ការតមអាហារក៏ជួយឲ្យយើងអាចយកឈ្នះលើទំលាប់អាក្រក់មួយចំនួនផងដែរ។

ការរៀបចំខ្លួនមុនពេលតមអាហារ

***បន្ទាប់មកលោកយ៉ូស្វេមានប្រសាសន៍ទៅកាន់ប្រជាជនថា៖« ចូរញែកខ្លួនអោយវិសុទ្ធ ដ្បិតថ្ងៃស្អែកព្រះអង្គម្ចាស់នឹងសម្តែងការអស្ចារ្យនៅកណ្តាលចំណោមអ្នករាល់គ្នា»។   (យ៉ូស្វេ៣:៥)***

អធិស្ឋាន—ចូរចំណាយពេលអានព្រះគម្ពីរ និងអធិស្ឋានមុនពេលតមអាហារ។ សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធជួយដឹកនាំពីអ្វីដែលត្រូវអធិស្ឋាន នៅទំព័រទី៩ដល់ទី១១។ ចូរសរសេរពីគោលដៅជំនឿ និងការអធិស្ឋានស្នើរសុំឲ្យបានជាក់លាក់សំរាប់ ក្រុមគ្រួសារ មិត្តភ័ក្រ្ត ក្រុមជំនុំ និងប្រជាជាតិរបស់លោកអ្នក។

ប្តេជ្ញាចិត្ត—ជ្រើសរើសប្រភេទនៃការតមអាហារ ហើយប្តេជ្ញាចិត្តធ្វើវាឲ្យបាន។ កត់ចំណាំនូវប្រភេទតមរបស់លោកអ្នកក្នុងទំព័រទី៨។ ចូរទូលសុំព្រះគុណពីព្រះអង្គ ក្នុងការធ្វើវាឲ្យបាន។

សកម្មភាព—កាត់បន្ថយការញ៉ាំបន្តិចម្តងៗ ១សប្តាហ៍ ឬបីថ្ងៃមុនពេលការតមអាហារមកដល់។ ជៀសវាងការញ៉ាំអាហារណាដែលមានជាតិស្ករ និងខ្លាញ់ច្រើន។ កាត់បន្ថយសកម្មភាពកម្លាំងកាយ យ៉ាងហោចណាស់មួយសប្តាហ៍មុនថ្ងៃតម និងក្នុងពេលតមអាហារ។ រកដៃគូរអធិស្ឋាន ឲ្យគេសរសេរឈ្មោះនៅទំព័រទី៧។

***កត់ចំណាំ:*** ***ប្រសិនបើអ្នកមានផ្ទៃពោះ ឬត្រូវបំបៅទារក ឬលេបថ្នាំជាប្រចាំ សូមពិគ្រោះជាមួយគ្រូពេទ្យជាមុនសិនមុនសម្រេចចិត្តតម។ បើលោកអ្នកស្ថិតក្នុងស្ថានភាពណាមួយដែលមិនអាចតមទាំងស្រុងបាន ចូរជ្រើសយកជំរើសណាមួយដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់លោកអ្នក។***

កំឡុងពេលតមអាហារ

***ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា‘មនុស្សមិនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ផងដែរ។ (ម៉ាថាយ៤:៤)***

*ផ្តោត—ទុកពេលជាមួយព្រះ និងបំពេញកូនសៀវភៅនេះ។ ត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការគោរពតាមព្រះបន្ទូល និងការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

*អធិស្ឋាន—ចូលរួមការប្រជុំអធិស្ឋានរបស់ក្រុមជំនុំ។ អធិស្ឋានឲ្យគ្រួសារ សាលារៀន គ្រូគង្វាល បេសកជនផ្សាយដំណឹងល្អ និងប្រជាជាតិរបស់លោកអ្នកមួយសប្តាហ៍ពេញ។*

*បំពេញជំនួស—យកពេលបរិភោគអាហារទៅអានព្រះគម្ពីរ និងអធិស្ឋាន។ផឹកទឹក និងសម្រាកឲ្យបានច្រើន តាមតែអាចធ្វើទៅបាន។ ត្រូវត្រៀមខ្លួនទទួលយកផលវិបាកមួយចំនួនដូចជា ភាពអស់កម្លាំង ឆាប់ឆេវឆាវ និងពិបាកទប់អារម្មណ៍ជាដើម។*

*បញ្ចប់ការតមអាហារ*

***ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វី ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្តាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្តាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។ ១យ៉ូហាន៥:១៤-១៥***

*បរិភោគ—បរិភោគអាហារឡើងវិញ បន្តិចម្តងៗ។ ក្រពះរបស់លោកអ្នកត្រូវការពេលវេលាដើម្បីសម្របទៅនឹងអាហារប្រចាំថ្ងៃឡើងវិញ។ ចាប់ផ្តើមដោយការបរិភោគបន្លែ ផ្លែឈើ និងទឹកផ្លែឈើស្រស់ ហើយបរិភោគបន្តិចម្តងៗ។*

*អធិស្ឋាន—កុំឈប់អធិស្ឋាន! ទុកចិត្តលើភាពស្មោះត្រង់ និងពេលវេលាត្រឹមត្រូវរបស់ព្រះជាម្ចាស់។ បន្តភាពក្តៀវក្លាសម្រាប់ព្រះអង្គពេញមួយឆ្នាំនេះ។ ត្រូវមានជំនឿថាព្រះជាម្ចាស់នឹងឆ្លើយតបការអធិស្ឋានរបស់លោកអ្នក។*

គំរោងតមរបស់ខ្ញុំ

ថ្ងៃទី១

ជំរើសប្រភេទតម:

☐ ញ៉ាំតែទឹកប៉ុណ្ណោះ
☐ ញ៉ាំតែរបស់រាវប៉ុណ្ណោះ
☐ ទទួលទានអាហារតែមួយពេល
☐ ផ្សេងៗ________

ការចូលរួមប្រជុំអធិស្ឋាន:

________________________

ថ្ងៃទី២

ជំរើសប្រភេទតម:

☐ ញ៉ាំតែទឹកប៉ុណ្ណោះ
☐ ញ៉ាំតែរបស់រាវប៉ុណ្ណោះ
☐ ទទួលទានអាហារតែមួយពេល
☐ ផ្សេងៗ________

ការចូលរួមប្រជុំអធិស្ឋាន:

________________________

ថ្ងៃទី៣

ជំរើសប្រភេទតម:

☐ ញ៉ាំតែទឹកប៉ុណ្ណោះ
☐ ញ៉ាំតែរបស់រាវប៉ុណ្ណោះ
☐ ទទួលទានអាហារតែមួយពេល
☐ ផ្សេងៗ________

ការចូលរួមប្រជុំអធិស្ឋាន:

________________________

ថ្ងៃទី៤

ជំរើសប្រភេទតម:

☐ ញ៉ាំតែទឹកប៉ុណ្ណោះ
☐ ញ៉ាំតែរបស់រាវប៉ុណ្ណោះ
☐ ទទួលទានអាហារតែមួយពេល
☐ ផ្សេងៗ________

ការចូលរួមប្រជុំអធិស្ឋាន:

________________________

ថ្ងៃទី ៥

ជំរើសប្រភេទតម:

☐ ញ៉ាំតែទឹកប៉ុណ្ណោះ
☐ ញ៉ាំតែរបស់រាវប៉ុណ្ណោះ
☐ ទទួលទានអាហារតែមួយពេល
☐ ផ្សេងៗ________

ការចូលរួមប្រជុំអធិស្ឋាន:

________________________

ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់ . . .

សំណូមអធិស្ឋានដែលទទួលបានការឆ្លើយតបពីព្រះជាម្ចាស់
សរសេរចំណុចសំខាន់ៗ, សំណូមអធិស្ឋានដែលទទួលបានការឆ្លើយតបពីព្រះជាម្ចាស់, និងបទពិសោធ ដែលបានឆ្លងកាត់ក្នុងឆ្នាំ២០២០

នៅក្នុងឆ្នាំ២០២១, ខ្ញុំជឿជាក់ព្រះជាម្ចាស់សម្រាប់. . .

**គោលដៅសេចក្តីជំនឿផ្ទាល់ខ្លួន**

- ការផុសផុលខាងវិញ្ញាណ• ការប្រោសឲ្យជា • ភាពចម្រុងចម្រើន និងភាពសម្បូរហូរហៀរ • ការឲ្យដោយចិត្តសប្បុរស . . .

**ក្រុមគ្រួសាររបស់ខ្ញុំ**

- ការស្តារឡើងវិញនៃទំនាក់ទំនងក្នុងគ្រួសារ • សេចក្តីសង្គ្រោះដល់សមាជិកក្រុមគ្រួសារទាំងមូល . . .

**ការសិក្សា/ការងាររបស់ខ្ញុំ**

- ល្អប្រសើ • តម្លើងឋានៈ . . .

**ព័ន្ធកិច្ចរបស់ខ្ញុំ**

- ការលូតលាស់ក្រុមតូច • សេចក្តីសង្គ្រោះសម្រាប់មិត្តរួមការងារ និងមិត្តរួមថ្នាក់ . . .

---

*ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ទៀតថា ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើមានពីរនាក់នៅលើផែនដីនេះ រួមចិត្តគំនិតគ្នា ទូលសូមអ្វីក៏ដោយ ព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខនឹងប្រទានអោយជាមិនខាន" ម៉ាថាយ១៨:១៩*

**ដៃគូអធិស្ឋានរបស់ខ្ញុំ:** ______________________________

ខ្ញុំប្តេជ្ញាអធិស្ឋានសម្រាប់ . . .

| ឈ្មោះ | សំណូមអធិស្ឋាន |
|---|---|

ខ្ញុំប្ដេជ្ញាអធិស្ឋានសម្រាប់ . . .

**ក្រុមជំនុំរបស់ខ្ញុំ**

- ថ្នាក់ដឹកនាំក្រុមជំនុំ • ការផ្គត់ផ្គង់ • ព័ន្ធកិច្ចបង្កើតសិស្សសាវ័ក . . .

**សហគមន៍របស់ខ្ញុំ**

- សាលា និងវិទ្យាស្ថានអប់រំ • រដ្ឋាភិបាលក្នុងស្រុក • ឱកាសផ្សព្វផ្សាយតាមតំបន់ផ្សេងៗ . . .

**ប្រជាជាតិរបស់ខ្ញុំ**

- មន្ត្រីរដ្ឋាភិបាល • ការផុសផុលខាងវិញ្ញាណ • ភាពចម្រុងចម្រើនផ្នែកសេដ្ឋកិច្ច • សន្តិភាព និងរបៀបរៀបរយ . . .

បច្ចុប្បន្នក្រុមជំនុំគ្រប់ជាតិសាសន៍ បានធ្វើការរួចមកហើយនៅក្នុង85 ប្រទេស
សូមបន្តអធិស្ឋានសម្រាប់ប្រទេសដែលនៅសល់ចំនួន115 ប្រទេស ហើយយើងជឿថាព្រះជាម្ចាស់នឹងបើកទ្វារ
សម្រាប់ការដាំក្រុមជំនុំបន្ថែមទៀត

Afghanistan
Albania
Algeria
Andorra
Angola
Antigua
Barbuda
Azerbaijan
Argentina
Bahamas
Barbados
Belarus
Belize
Benin
Bosnia and
Herzegovina
Bulgaria
Burkina Faso
Cabo Verde
Cameroon
Central African
Republic
Chad

Comoros

Congo
Costa Rica
Côte d’Ivoire
Croatia
Cuba
Cyprus
Czech Republic
Democratic
Republic of the
Congo
Denmark
Djibouti
Dominica
Ecuador
Egypt
El Salvador
Equatorial
Guinea
Eritrea
Estonia
Ethiopia
Finland
Gambia
Greece
Grenada

Guatemala
Guinea
Guinea-Bissau
Guyana
Haiti
Hungary
Iceland
Iraq
Israel
Italy
Jamaica
Kenya
Kiribati
Latvia
Lebanon
Lesotho
Libya
Liechtenstein
Lithuania
Luxembourg
Macedonia
Madagascar
Mali
Malta
Marshall Islands

Mauritania
Mauritius
Moldova
Monaco
Montenegro
Morocco
Nauru
Nicaragua
Niger
North Korea
Norway
Palau
Palestine
Paraguay
Russia
Rwanda
Saint Kitts and
Nevis
Saint Lucia
Saint Vincent and
the Grenadines
Samoa
San Marino
Sao Tome and
Principe

Senegal
Serbia
Seychelles
Sierra Leone
Slovakia
Slovenia
Solomon Islands
Somalia
South Sudan
Sudan
Suriname
Switzerland
Syria
Tanzania
Tonga
Trinidad and
Tobago
Tunisia
Turkmenistan
Tuvalu
Uruguay
Uzbekistan
Vanuatu
Vatican City
Yemen



***បើព្រះអង្គសុំ យើងនឹងប្រគល់ប្រជាជាតិនានាអោយព្រះអង្គទុកជាមត៌កយើងក៏នឹងប្រគល់ផែនដីទាំងមូលអោយព្រះអង្គទុកជាកម្មសិទ្ធិដែរ។*** *ទំនុកតម្កើង២:៨*

អធិស្ឋានសម្រាប់ការដាំក្រុមជំនុំថ្មី ដូចដែលពួកគេបង្កើតសិស្សសាវ័ក ព្រមទាំងឃើញពីសេចក្តីត្រូវការនៅក្នុងសហគមន៍របស់ពួកគេ និងចែកចាយដំណឹងល្អនៃព្រះយេស៊ូគ្រិស្តនៅក្នុងទីក្រុងថ្មីរបស់ពួកគេ។

*អាមេនី*
*អូស្រ្តាលី*
*អាហ្សង់ទីន*
*បុតស្វាវ៉ា*
*ប្រេស៊ីល*
*ប្រ៊ុយនេ*
*កាណាដា*
*ចិន*
*បារាំង*
*ហ្សកហ្ស៊ី*
*ហុងកុងគូរ៉ាស*
*ឥណ្ឌា*
*ឥណ្ឌូនេស៊ី*
*អ៊ីរ៉ង់*
*ជប៉ុន*
*កេនយ៉ា*
*ឡាវ*
*ម៉ាកាវ*
*ម៉ាឡាវី*
*ម៉ាល់ឌីវ*
*ម៉ូរីស*
*ម៉ិកស៊ិក*
*ម៉ុងហ្គូលី*
*ម៉ូសំប៊ិក*
*ហូល្លង់*
*នូវែលសេឡង់*
*ប៉ាណាម៉ា*
*ភីលីពីន*
*ប៉ូទុយហ្គាល់*
*រូម៉ានី*
*ស្កុតលេន*
*ស៊ិងហ្គាពួរ*
*អាហ្វ្រិកខាងត្បូង*
*ស្រីលង្កា*
*ស៊ុយអែត*
*តៃវ៉ាន់*
*តាជីគីស្ថាន*
*ថៃ*
*ទីម័រខាងកើត*
*អ៊ូហ្គង់ដា*
*សហភាពអារ៉ាប់រួម*
*សហរដ្ឋអាមេរិច*
*យូហ្សាបេគីស្ថាន*
*វៀតណាម*
*ហ្សំបៀ*

## ព័ន្ធកិច្ចតាមសាលា

***«. . . ហេតុនេះ ចូរអង្វរម្ចាស់ស្រែ អោយចាត់អ្នកច្រូតមកក្នុងស្រែរបស់លោក»*** *ម៉ាថាយ៩:៣៨*

### អធិស្ឋានសម្រាប់:

- ការភ្ជាប់ទំនាក់ទំនងជាមួយសិស្សថ្មីជាមួយដំណឹងល្អនៅក្នុងឆ្នាំនេះ
- បេសកជនតាមសាលា និងសមាជិកក្រុមជំនុំទទួលបានប្រាជ្ញាក្នុងការផ្សព្វផ្សាយដំណឹងល្អ និងការបង្កើតសិស្សសាវ័កនៅតាមសកលវិទ្យាល័យ
- ការទទួលបានការអនុញ្ញាត ឬការយល់ព្រមពីសកលវិទ្យាល័យ ដើម្បីទទួលបានការផ្សារភ្ជាប់ទំនាក់ទំនងជាមួយសិស្សានុសិស្ស
- សេចក្តីសុខសាន្តសម្រាប់សិស្សានុសិស្សដែលរងផលបះពាល់ដោយសារជំងឺកូវីត១៩
- ការផ្គត់ផ្គង់សម្រាប់សិស្សានុសិស្សដែលបានរងផលប៉ះពាល់ដោយសារជំងឺកូវីត១៩
- បេសកជនតាមសាលាទទួលបានប្រាជ្ញា ដើម្បីរកវិធីសាស្រ្តល្អៗជួយដល់សិស្សានុសិស្ស



*9:38 Challenge:* កំណត់នាឡិការោទ៍ ម៉ោង៩:៣៨នាទីព្រឹក (ឬល្ងាច តាមពេលវេលាដែលសមស្របសម្រាប់លោកអ្នក)។ រាល់ពេលដែលនាឡិការោទ៍ សូមឆ្លៀតពេលបន្តិចដើម្បីអធិស្ឋានទៅកាន់ព្រះជាម្ចាស់ សូមឲ្យទ្រង់បញ្ជូនបេសកជន និងអ្នកដាំក្រុមជំនុំបន្ថែមទៀត ដែលមានភាពក្លាហានក្នុងការប្រកាសដំណឹងល្អរហូតដល់អវសានកាលនៃពិភពលោក។

# ព្រះជាម្ចាស់ អស្ចារ្យ និងល្អ

អេសាយ៥៧:១៥

***ដ្បិតព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលគង់នៅអស់កល្បជានិច្ច ហើយដែលមានព្រះនាមដ៏វិសុទ្ធបំផុតមានព្រះបន្ទូលថា:យើងស្ថិតនៅក្នុងស្ថានដ៏ខ្ពង់ខ្ពស់បំផុត និងជាស្ថានដ៏វិសុទ្ធមែន តែយើងក៏ស្ថិតនៅជាមួយមនុស្សដែលត្រូវគេសង្កត់សង្កិន និងមនុស្សដែលគេមើលងាយដែរ ដើម្បីលើកទឹកចិត្តមនុស្សដែលគេមើលងាយ និងមនុស្សរងទុក្ខខ្លោចផ្សា។***

អានបន្ថែម: យេរេមា១០:៦; វិវរណៈ៤:១១; ទំនុកតម្កើង១០៦:១; ទំនុកតម្កើង១១៩:៦៨,
(ជម្រើសបន្ថែម: លូកា១៨:១៩)

នៅក្នុងគំរូកម្រងមេរៀនរបស់កុមារ របាក្សត្រនៃណានីយ៉ា អ្នកអានជាញឹកញាប់ត្រូវរំលឹកថា អាសឡាន គឺមិនមែនជាអ្នកផ្សាំុសត្វតោនោះទេ។ នៅពេលដែលបងស្រីភើរែនស៊ី, ស៊ូសានបានប្រាប់ថា អាសឡានគឺជាសត្វតោ នាងនិយាយថា ខ្ញុំបានគិតថាគាត់ជាមនុស្ស តើគាត់មិនមែនជាមនុស្សដែលគួរឲ្យទុកចិត្តដែរទេឬ? លោកបៀវើដែលជាបុរសរួសរាយឆ្លើយតបថា “គួរឲ្យទុកចិត្ត? . . . តើនរណានិយាយថាគួរឲ្យទុកចិត្ត? ពិតណាស់គាត់មិនគួរឲ្យទុកចិត្តទេ ប៉ុន្តែខ្ញុំប្រាប់អ្នក គាត់ជាមនុស្សល្អ គាត់គឺជាស្ដេច។

ដូចជាស៊ូសាន នាងជាអ្នកដែលបានភន់ច្រឡំចំពោះអាសឡាន។ ជារឿយៗ យើងក៏បានភាន់ច្រឡំចំពោះព្រះជាម្ចាស់ផងដែរ។ មានការភាន់ច្រឡំជាច្រើនបានកើតឡើង នៅពេលដែលយើងនិយាយបន្ទូរស្ថានការណ៍ណាមួយពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់ ឬក៏ភាពល្អរបស់ព្រះអង្គ។ ពេលយើងនិយាយពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់ យើងចាត់ទុកថានោះជាបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ ហើយវាជាកម្មសិទ្ធរបស់ទ្រង់តែមួយព្រះអង្គ។ វាហាក់បីដូចជាភាពជាក់លាក់ និងភាពមាននៅគ្រប់ទីកន្លែង។ ពេលយើងនិយាយពីភាពល្អរបស់ព្រះជាម្ចាស់ យើងចាត់ទុកថានោះជាបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ ដែលមនុស្សគ្រប់គ្នាក៏អាចមានផងដែរ ដូចជា ការអាណិតអាសូរ និងការប្រណីសន្តោស។ ប្រសិនលោកអ្នកគ្រាន់តែផ្តោតលើ ភាពអស្ចារ្យរបស់ព្រះជាម្ចាស់ លោកអ្នកប្រហែលជាពិបាកជឿថាព្រះអង្គស្រឡាញ់លោកអ្នក ជាពិសេសនៅពេលលោកអ្នកស្ថិតនៅក្រោមបញ្ហា និងទុក្ខលំបាកជាច្រើន។ ប៉ុន្តែប្រសិនបើលោកអ្នកគ្រាន់តែផ្តោតលើ សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ លោកអ្នកប្រហែលចាប់ផ្តើមគិតពីព្រះអង្គ ដូចជា “អ្នកផ្សាំុសត្វតោ” ដែលខ្វះអំណាច។

នៅក្នុងព្រះគម្ពីរ អេសាយជំពូក៥៧ ព្យាការីបន្ទោសដល់ប្រជាជនអ៊ីស្រ៉ាអែល សម្រាប់ភាពមិនស្មោះត្រង់របស់ពួកគេ។ ជំនួសឲ្យការថ្វាយបង្គំព្រះពិតតែមួយ ពួកគេបានបែរទៅថ្វាយបង្គំព្រះក្លែងក្លាយនៃប្រទេសជុំវិញទៅវិញ។ ប្រជាជនមិនបាននឹកចាំពីព្រះជាម្ចាស់ដ៏អស្ចារ្យ និងសប្បុរសរបស់ពួកគេទេ ប្រសិនបើពួកគេនឹកចាំមែន ពួកគេមិនបែរទៅថ្វាយបង្គំព្រះដទៃនោះឡើយ។

ព្យាការីអេសាយធ្លាប់បានបង្ហាញចេញយ៉ាងអស់ពីចិត្ត ពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់។ ជារឿយៗការថ្វាយព្រះនាមទ្រង់ គឺជាព្រះដ៏វិសុទ្ធតែមួយនៃអ៊ីស្រ៉ាអែល។ គាត់បានរំលឹកដល់ប្រជាជនទាំងអស់ថា ព្រះជាម្ចាស់គឺជាព្រះដ៏មានគ្រប់ទាំងអំណាចព្រះចេស្ដា ដែលគង់នៅស្ថានដ៏ខ្ពស់ និងជាកន្លែងដ៏វិសុទ្ធ និងមានព្រះជន្មគង់នៅជារៀងរហូត។ ប៉ុន្តែព្យាការីអេសាយមិនបានឈប់ប្រកាសត្រឹមនេះនោះឡើយ។ គាត់ថែមទាំងរំលឹកប្រជាជនទាំងអស់ថា ព្រះជាម្ចាស់គឺព្រះជាម្ចាស់តែមួយ ទ្រង់ក៏គង់ជាមួយអស់អ្នកដែលមានភាពខ្សត់ខ្សោយខាងឯវិញ្ញាណផងដែរ។ ព្រះអង្គមិនត្រឹមតែជាព្រះដ៏អស្ចារ្យ មហិមា

និងវិសុទ្ធ ប៉ុន្តែព្រះជាម្ចាស់ទ្រង់ល្អ ទ្រង់ប្រោះអស់អ្នកដែលត្រឡប់មកកាន់ព្រះអង្គឲ្យរស់ឡើងវិញ នៅពេលគេបន្ទាបខ្លួន និងប្រែចិត្ត។ ពិតប្រាដកថា ព្រះអង្គតែមួយដែលសាកសមលើសអ្វីៗទាំងអស់នៃការថ្វាយបង្គំរបស់យើង។

ប៉ុន្តែជារឿយៗ យើងដូចជាប្រជាជនអ៊ីស្រាអែលដែរ។ យើងភ្លេចថា ព្រះដ៏អស្ចារ្យ និងល្អរបស់យើង តើទ្រង់ធំមហិមាប៉ុណ្ណា។ យើងអនុញ្ញាតឲ្យមនុស្សដទៃ គោលបំណង គំនិត គោលដៅ សុបិន្ត និងអ្វីផ្សេងទៀតមកលួចយកការថ្វាយបង្គំ ដោយទ្រង់តែមួយដែលសាកសមនឹងទទួលបានការថ្វាយបង្គំនេះ។ សប្តាហ៍នេះ យើងនឹងស្វែងយល់ពីបុគ្គលិកលក្ខណៈនៃព្រះជាម្ចាស់ ២ផ្នែក: ភាពអស្ចារ្យ និងភាពល្អរបស់ទ្រង់។ ក្នុងការពិចារណាពី ភាពអស្ចារ្យរបស់ព្រះអង្គ យើងនឹងសិក្សាថា ព្រះអង្គខ្ពង់ខ្ពស់លើសអ្វីទាំងអស់ មិនដែលផ្លាស់ប្រែ និងសោយរាជ្យលើអ្វីៗទាំងអស់។ ក្នុងការក្រឡេកមកមើលចំពោះភាពល្អរបស់ព្រះអង្គ យើងនឹងឃើញថាព្រះជាម្ចាស់យុត្តិធម៌ អត់ធ្មត់ និងមានព្រះហឫទ័យសប្បុរស។ ដូចដែលយើងសញ្ជឹងគិតលើ ភាពអស្ចារ្យ និងភាពល្អរបស់ព្រះអង្គនៅសប្តាហ៍នេះ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធ បើកសម្តែងមកកាន់គំនិតភាន់ច្រឡំ និងលាក់អស់ទាំងរូបព្រះក្លែងក្លាយរបស់យើង ហើយយើងអាចបន្តថ្វាយអស់ទាំងការថ្វាយបង្គំរបស់យើងទៅកាន់ព្រះអង្គតែមួយដែលទ្រង់សាកសមនឹងទទួលបានការថ្វាយបង្គំនេះ។

ពីព្រោះព្រះជាម្ចាស់គឺអស្ចារ្យ និងល្អ ព្រះអង្គសមនឹងទទួលការថ្វាយបង្គំរបស់យើង

**ការឆ្លុះបញ្ចាំង**

តើផ្នែកណាមួយនៃចរិកលក្ខណៈរបស់ព្រះជាម្ចាស់ ដែលពិបាកសម្រាប់លោកអ្នកក្នុងការជឿ?ភាពអស្ចារ្យរបស់ព្រះអង្គ ឬភាពល្អរបស់ព្រះអង្គ? ហេតុអ្វី?

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

រៀបរាប់ហេតុផលទាំងអស់ដែលលោកអ្នកជឿថាព្រះជាម្ចាស់សាកសមនឹងថ្វាយបង្គំ:

________________________________________

________________________________________

________________________________________

________________________________________



# ការអធិស្ឋាន

*ដ្បិតព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលគង់នៅអស់កល្បជានិច្ច ហើយដែលមានព្រះនាមដ៏វិសុទ្ធបំផុតមានព្រះបន្ទូលថា:យើងស្ថិតនៅក្នុងស្ថានដ៏ខ្ពង់ខ្ពស់បំផុត និងជាស្ថានដ៏វិសុទ្ធមែន តែយើងក៏ស្ថិតនៅជាមួយមនុស្សដែលត្រូវគេសង្កត់សង្កិន និងមនុស្សដែលគេមើលងាយដែរ ដើម្បីលើកទឹកចិត្តមនុស្សដែលគេមើលងាយ និងមនុស្សរងទុក្ខខ្លោចផ្សា។*

អេសាយ៥៧:១៥

*ឱ ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ គ្មាននរណាមួយឲ្យដូចទ្រង់។ ព្រះអង្គជាព្រះដ៏អស្ចារ្យ ពេញដោយព្រះចេស្ដា និងរិទ្ធីអំណាច ព្រះអង្គថែមទាំងល្អ សប្បុរស និងយុត្តិធម៌។ គ្មានចរិកលក្ខណ:ណាមួយរបស់ព្រះអង្គគ្របបាំងលើគ្នាឡើយ។ ព្រះអង្គសាកសមនឹងទទួលបានការថ្វាយបង្គំរបស់ខ្ញុំ មិនមែនដោយសារតែអ្វីដែលព្រះអង្គបានធ្វើសម្រាប់ខ្ញុំតែប៉ុណ្ណោះនោះទេ ប៉ុន្តែភាពជាព្រះរបស់ព្រះអង្គ។ ព្រះអង្គជាព្រះដ៏គួរអោយស្ញប់ស្ញែង។ ព្រះអម្ចាស់ ខ្ញុំអធិស្ឋានសូមឲ្យ សប្តាហ៍នេះ ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ នឹងបង្រៀនខ្ញុំឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងពីភាពអស្ចារ្យ និងភាពល្អរបស់ទ្រង់។ សូមបើកភ្នែករបស់ខ្ញុំឲ្យមើលឃើញថាទ្រង់កំពុងធ្វើការក្នុងជីវិតខ្ញុំ និងក្នុងលោកិយ៍នេះទាំងមូល។ ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ទ អាម៉ែន។*

ថ្ងៃទី១

# ព្រះជាម្ចាស់

## អស្ចារ្យលើសអ្វីៗទាំងអស់

និក្ខមនំ១៥:១១

*“ព្រះអម្ចាស់អើយ តើមានព្រះណាអាចផ្ទឹមនឹងព្រះអង្គបាន?តើនរណាមានភាពថ្កុំថ្កើងដ៏វិសុទ្ធដូចព្រះអង្គ។ព្រះអង្គជាព្រះគួរអោយកោតស្ញប់ស្ញែងគួរសរសើរតម្កើងព្រះអង្គសំដែងឫទ្ធិបាដិហារិយ៍ដ៏អស្ចារ្យ។”*

*អានបន្ថែម: ទុតិយកថា៣:២៤; ២សាំយូអែល៧:២២; អេភេសូ៤:៤–៦; ហេប្រឺ១:៣*

ភ្នំថាប៊ល ក្នុងក្រុងកេព នៅប្រទេសអាហ្វ្រិកខាងត្បូង គឺជាភ្នំមួយដែលល្បីល្បាញបំផុតក្នុងចំណោមភ្នំជាច្រើននៅក្នុងពិភពលោក។ ខណៈពេលដែលភ្នំនេះមានភាពស្រស់ស្អាតតាំងពីក្រោមរហូតដល់លើ ហើយការទស្សនាពីកំពូលភ្នំទៅគឺពិតជាធ្វើអោយរំភើបនឹងអស្ចារ្យជាខ្លាំង ក្បាលរបស់សត្វគោ ជំរុំបែ និងសារីកទាំងដប់ពីរ។ គ្មានអ្វីអាចប្រៀបផ្ទឹមស្មើទៅនឹងការឈរនៅលើចំណុចកំពូលភ្នំ គយគន់មើលពិភពលោកនៅជុំវិញខ្លួនលោកអ្នកនោះឡើយ។ ប៉ុន្តែនៅចំណុចខ្លះ យើងទាំងអស់គ្នាត្រូវតែចាកចេញពីចំណុចនៃកំពូលភ្នំ ហើយធ្វើដំណើរយ៉ាងឆ្ងាយត្រឡប់មកក្រោមវិញ ដើម្បីទៅកាន់ភាពជាក់ស្តែង។

ជាការអរគុណ ភាពដូចគ្នាគឺមិនមែនជាការពិតសម្រាប់ព្រះជាម្ចាស់ដ៏គួរអោយស្ញប់ស្ញែងរបស់យើងនោះឡើយ។ ក្នុងនាមព្រះអង្គជាព្រះដែលបង្កើតគ្រប់អ្វីទាំងអស់ ព្រះអង្គគឺជាព្រះដែលអស្ចារ្យលើសអ្វីទាំងអស់។ មានន័យថា ព្រះអង្គខុសពីអ្វីៗទាំងអស់ដែលបានបង្កើតមក ហើយលើសពីច្បាប់ធម្មជាតិ។ ព្រះអង្គគង់នៅកន្លែងដែលខ្ពស់ និងវិសុទ្ធ ហើយក៏គ្មានអ្វីនៅក្នុងលោកិយ៍នេះដូចទ្រង់នោះឡើយ។ ព្រះអង្គប្រើប្រាស់ការគ្រប់គ្រង និងអំណាចនៅលើអ្វីៗទាំងអស់ ហើយគ្មានការអស្ចារ្យណាមួយដែលព្រះអង្គធ្វើមិនបាននោះឡើយ។

នៅក្នុងព្រះគម្ពីរនិក្ខមនំជំពូក១៥ ម៉ូសេ និងប្រជាជនអ៊ីស្រាអែលបានលើកបទចម្រៀងសសើរថ្វាយព្រះអម្ចាស់ បន្ទាប់ពីទ្រង់បានធ្វើការយ៉ាងអស្ចារ្យញែកសមុទ្រក្រហម និងសង្គ្រោះពួកគេពីកណ្តាប់ដៃរបស់ស្តេចផារោន។ បន្ទាប់ពីពួកគេបានឃើញអំណាចដ៏អស្ចារ្យលើសអ្វីៗទាំងអស់របស់ព្រះជាម្ចាស់ដែលទ្រង់បានធ្វើនោះ ពួកគេច្រៀងថា“ព្រះអម្ចាស់ អើយ តើមានព្រះណាអាចផ្ទឹមនឹង ព្រះអង្គបាន? តើនរណាមានភាពថ្កុំថ្កើងដ៏វិសុទ្ធដូចព្រះអង្គ។ ព្រះអង្គជាព្រះគួរឲ្យកោតស្ញប់ស្ញែង គួរសរសើរតម្កើងព្រះអង្គសម្តែងឫទ្ធិបាដិហារិយ៍ដ៏អស្ចារ្យ។” ក្នុងពេលដែលវាយជាមួយនឹងពួកសាសន៍អេស៊ីព្ទ ព្រះអម្ចាស់បានបង្ហាញថា ព្រះអង្គមានគ្រប់ទាំងព្រះចេស្តាជាងព្រះរបស់ពួកសាសន៍អេស៊ីព្ទទៅទៀត។ គ្មានឧបសគ្គណាមួយឬក៏ការទាស់ប្រឆាំងណាដែលធំពេក សម្រាប់ព្រះដែលគួរអោយកោតស្ញប់ស្ញែងរបស់យើងនោះឡើយ។

ដូចដែលយើងនឹងចាប់ផ្តើមក្នុងសប្តាហ៍នេះ ពីការអធិស្ឋានតប យើងនឹងប្រទះជាមួយនឹងឧបសគ្គនិងការទាស់ប្រឆាំងរបស់យើង ទៅនឹងសេចក្តីជំនឿរបស់យើង។ លោកអ្នកប្រហែលជាអធិស្ឋានពីសេចក្តីសង្គ្រោះសម្រាប់មនុស្សជាទីស្រឡាញ់របស់លោកអ្នក ឬក៏ការប្រោសឲ្យជាសម្រាប់នរណាម្នាក់ដែល

ជិតស្និទ្ធនឹងលោកអ្នក ឬក៏ការទម្លុះទម្លាយផ្នែកហិរញ្ញវត្ថុ។ ឬក៏លោកអ្នកកំពុងតែដោះស្រាយជាមួយនឹងការសាកល្បង សេចក្ដីល្បួងផ្សេងៗ ឬក៏តេស្តក្នុងសេចក្ដីជំនឿរបស់លោកអ្នក។ លោកអ្នកកំពុងតែថ្វាយវាទៅព្រះជាម្ចាស់ ហើយអំពាវនាវទៅកាន់ទ្រង់សម្រាប់ការអស្ចារ្យ។ ត្រូវតែស្ថិតជាប់ក្នុងសេចក្ដីជំនឿ ពីព្រោះព្រះជាម្ចាស់ស្ថិតនៅលើអ្វីៗទាំងអស់ដែលព្រះអង្គបង្កើតមក ព្រះអង្គអាចញែកទឹកសមុទ្រ ប្រទាននំម៉ាណាពីស្ថានសួគ៍ ហើយថែមទាំងប្រទានទឹកផឹកដែលចេញពីថ្មផងដែរ។ តាមរយៈព្រះអង្គ យើងអាចជឿបានថា ការអស្ចារ្យគឺអាចកើតឡើងបាន។

**ដោយព្រោះព្រះជាម្ចាស់គឺអស្ចារ្យលើសអ្វីៗទាំងអស់ នោះការអស្ចារ្យទាំងអស់ក៏អាចកើតឡើងបានដែរ។**

កំណត់សម្គាល់

___

___

___

___

___

___

___

ការឆ្លុះបញ្ចាំង

តើបច្ចុប្បន្នលោកអ្នកកំពុងជួបប្រទះឧបសគ្គ ឬក៏ការទាស់ប្រឆាំងទៅនឹងសេចក្ដីជំនឿរបស់លោកអ្នកដែរឬទេ? តើនោះជាអ្វី?

___

___

___

___

___

___

តើលោកអ្នករកឃើញថាវាងាយស្រួលឬលំបាកក្នុងការជឿថាព្រះជាម្ចាស់អាចធ្វើការអស្ចារ្យក្នុងជីវិតរបស់លោកអ្នកបាន? តើការសញ្ជឹងគិតលើភាពអស្ចារ្យលើសអ្វីៗទាំងអស់របស់ព្រះជាម្ចាស់បែបណាដែលអាចបង្កើនសេចក្តីជំនឿរបស់លោកអ្នកបាន?

*“ ព្រះអម្ចាស់អើយ តើមានព្រះណាអាចផ្ទឹមនឹងព្រះអង្គបាន?តើនរណាមានភាពថ្កុំថ្កើងដ៏វិសុទ្ធដូចព្រះអង្គ។ព្រះអង្គជាព្រះគួរអោយកោតស្ញប់ស្ញែងគួរសរសើរតម្កើងព្រះអង្គសំដែងឫទ្ធិបាដិហារិយ៍ដ៏អស្ចារ្យ។”*

និក្ខមនំ ១៥:១១

*ព្រះបិតាដែលគង់នៅស្ថានសួគ៌ ព្រះអង្គជាព្រះដែលត្រូវបានតម្កើងឡើងនៅស្ថានសួគ៌ដ៏ខ្ពស់ ហើយទ្រង់គង់នៅក្បែរបុត្រាបុត្រីរបស់ព្រះអង្គ។ កូនសូមសម្រាកនៅក្នុងសេចក្តីពិតដែលព្រះ*

*អង្គជាព្រះដ៏អស្ចារ្យលើសអ្វីៗទាំងអស់ និងពោរពេញដោយឫទ្ធានុភាព។ តាមរយៈព្រះអង្គ ដ្បិតគ្មានការអ្វីដែលមិនអាចទៅរួចនោះឡើយ។ ប្រជាជនអ៊ីស្រាអែលបានឃើញការអស្ចារ្យដែលព្រះអង្គបានធ្វើពេលដែលព្រះអង្គញែកសមុទ្រក្រហម ហើយពេលនេះកូនក៏សូមឲ្យព្រះអង្គបានដកអស់ទាំងបញ្ហាដែលកូនប្រឈមនៅថ្ងៃនេះចេញផងដែរ។ ព្រះអង្គតែមួយដែលគួរអោយស្ញប់ស្ញែង ក្នុងសិរីរុងរឿងរបស់ទ្រង់ ហើយកូនសូមអរគុណដែលព្រះអង្គតែងតែលឺសេចក្តីអធិស្ឋានរបស់កូន។ កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។*

ថ្ងៃទី ២

# ព្រះជាម្ចាស់

# មិនប្រែប្រួល

ហេប្រឺ ៦:១៧

*ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យបង្ហាញអោយអស់អ្នកដែលទទួលមត៌កតាមព្រះបន្ទូលសន្យា បានដឹងរឹតតែច្បាស់ថា បើព្រះអង្គសំរេចព្រះហឫទ័យយ៉ាងណាហើយនោះ ទ្រង់មិនប្រែប្រួលទេ។ ហេតុនេះ ព្រះអង្គមានព្រះបន្ទូលស្បថថែមលើព្រះបន្ទូលសន្យាទៀត។*

អានបន្ថែម: ជនគណនា ២៣:១៩; ទំនុកតម្កើង ១០២:២៥–២៧; ហេប្រឺ ១៣:៨; យ៉ាកុប ១:១៧ (ជម្រើសបន្ថែម: ម៉ាឡាគី ៣:៦)

ដុំស្កុតត្រូវបានបង្កើតឡើងនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ វាជាសំភារៈការពារជំរាបទឹកដែលចាប់តាមកៅស៊ូ។ ចាប់ពីពេលនោះមក ដុំស្កុតក៏ចាប់ផ្តើមមានប្រជាប្រិយភាពយ៉ាងខ្លាំងសម្រាប់ភាពជាប់បានយូរអង្វែង។ វាហាក់ដូចជាសម្ភារៈដែលនៅប្រើប្រាស់ជាប់បានយូរដែលបច្ចុប្បន្ននេះត្រូវបានប្រេីប្រាស់ធម្មតាដោយអ្នកជំនាញឌីអាយវ៉ាយ DIY) ដើម្បីបង្កើតរបស់ផ្សេងៗទៀតពីសម្លៀកបំពាក់ទៅជាទូកតូចម្យ៉ាង។ នៅក្នុងភាពយន្តឆ្នាំ២០១៥ ដឹម៉ូនថេន The Mountain) តារាសម្តែងម៉ាត់ ដាម៉ុន Matt Damon) នៅតែប្រើប្រាស់ដុំស្កុតសម្រាប់ជួសជុលនៅលើMars! ដុំស្កុតមានប្រជាប្រិយភាពរបស់វា ពីព្រោះតែភាពរឹងមាំ និងភាពគួរអោយទុកចិត្តបាន។ អ្នកដែលបង្កើតវាបានសន្យានឹងយើងថា វាមិនជ្រាបទឹក និងជាប់បានយូរ ហើយពួកគេដឹកជញ្ជូនវាគ្រប់ពេលវេលា។

ថ្ងៃនេះ យើងកំពុងបន្តទទួលស្គាល់ថា ព្រះជាម្ចាស់មិនប្រែប្រួល ព្រះអង្គនៅដដែល។ ភាពមិនផ្លាស់ប្តូររបស់ព្រះអង្គយោងទៅលើការពិតនៃចរិតលក្ខណៈ និងគោលបំណងដ៏អស់កល្បរបស់ទ្រង់ដែលមិនបានផ្លាស់ប្តូរ។ ម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត ព្រះអង្គនៅតែដដែល។ ព្រះអង្គគង់វង្សនៅជារៀងរហូត និងគួរអោយទុកចិត្ត។ សេចក្តីពិតនេះ គឺផ្តល់ឲ្យយើងមានភាពធូរស្បើយ ក្នុងពិភពលោកដែលពោរពេញដោយការប្រែប្រួល និងមិនទៀងទាត់នេះ។ ពីព្រោះព្រះជាម្ចាស់មិនដែលប្រែប្រួល ព្រះអង្គគួរឲ្យយើងជឿជាក់ និងមានសេចក្តីជំនឿបានយ៉ាងពិតប្រាកដ។

អ្នកចងក្រងព្រះគម្ពីរហេប្រឺនិយាយថា នៅពេលដែលព្រះជាម្ចាស់បានមានគោលបំណងបង្ហាញពីចរិតលក្ខណៈដែលមិនដែលប្រែប្រួលនៃគោលបំណងរបស់ព្រះអង្គ ព្រះអង្គបានធានាអះអាងវាជាមួយនឹងពាក្យសម្បថ។ អ្នកចងក្រងព្រះគម្ពីរនេះបន្តទៀតថា ផ្នែកនៃចរិតលក្ខណៈមិនប្រែប្រួលរបស់ព្រះជាម្ចាស់ ដែលវាមិនអាចទៅរួចសម្រាប់ព្រះអង្គ នោះគឺការកុហក។ វាមិនត្រឹមតែការដែលទុកចិត្តព្រះអង្គយ៉ាងពិតប្រាកដ ប៉ុន្តែយើងក៏អាចទុកចិត្តលើព្រះបន្ទូលរបស់ព្រះអង្គបានផងដែរ។ ប្រសិនបើព្រះអង្គមានបន្ទូលហើយ ព្រះអង្គនឹងធ្វើវា។ ប្រសិនបើព្រះអង្គបានសន្យាហើយ វានឹងបានសម្រេច។ ខណៈដែលព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា ចរិតលក្ខណៈ និងគោលបំណងរបស់ព្រះជាម្ចាស់គឺតែនៅដដែល យើងក៏អាចឃើញថាព្រះជាម្ចាស់ឆ្លើយតបមកកាន់សកម្មភាពរបស់យើង ដូចជាការអធិស្ឋាន និងជំនឿរបស់យើង។ ប៉ុន្តែការនេះមិនបានដាក់សម្ពាធមកលើយើងទេ ដូចដែលយើងត្រូវការការអធិស្ឋានជាវិធិសាស្រ្តដ៏ត្រឹមត្រូវ ឬជាការប្រមូលផ្តុំសេចក្តីជំនឿគ្រប់គ្រាន់ពីសមត្ថភាពនៃការគ្រប់គ្រងការគិតរបស់យើង។ ក្រៅពីនោះ សេចក្តីជំនឿដ៏ខ្លាំងក្លា គឺអាចធ្វើអោយការទាំងអស់អាចទៅរួច ដោយសារតែភាពទៀងទាត់នៃចរិតលក្ខណៈរបស់ព្រះជាម្ចាស់ និងភក្តីភាពនៃព្រះបន្ទូលរបស់

ព្រះអង្គ។ អធិស្ឋានជាមួយទំនុកចិត្តនៅសប្តាហ៍នេះ ដោយដឹងថាការឆ្ល ើយតបរបស់ព្រះជាម្ចាស់នឹងផ្តោតលើចរិតលក្ខណៈមិនប្រែប្រួល និងគោលបំណងដ៏នៅអស់កល្បរបស់ព្រះអង្គ។

## ពីព្រោះព្រះជាម្ចាស់មិនប្រែប្រួល សេចក្តីជំនឿរបស់យើងមានគ្រឹះដ៏រឹងមាំ។

កំណត់សម្គាល់

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

ការឆ្លុះបញ្ចាំង

តើការទុកចិត្តលើចរិតលក្ខណៈមិនប្រែប្រួល និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជួយលោកអ្នកក្នុងការមានសេចក្តីជំនឿដ៏រឹងមាំដោយរបៀបណា?

________________________________________________________________________

________________________________________________________________________

________________________________________________________________________



# ការអធិស្ឋាន

តើលោកអ្នកដឹងថាព្រះជាម្ចាស់នឹងឆ្លើយតបមកកាន់លោកអ្នកដោយផ្តោតលើចរិតលក្ខណៈដែលមិនប្រែប្រួល និងគោលបំណងដ៏នៅអស់កល្បជានិច្ចដែលមានឥទ្ធិពលលើរបៀបដែលលោកអ្នកអធិស្ឋានដោយរបៀបណា?

**ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យបង្ហាញអោយអស់អ្នកដែលទទួលមត៌កតាមព្រះបន្ទូលសន្យា បានដឹងរឹតតែច្បាស់ថា បើព្រះអង្គសំរេចព្រះហឫទ័យយ៉ាងណាហើយនោះ ទ្រង់មិនប្រែប្រួលទេ។ ហេតុនេះ ព្រះអង្គមានព្រះបន្ទូលស្បថថែមលើព្រះបន្ទូលសន្យាទៀត។**

ហេប្រឺ ៦:១៧

ព្រះអម្ចាស់ ព្រះអង្គជាទីជម្រកដែលប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សគ្រប់ជំនាន់ទាំងអស់។ ព្រះអង្គមិនកុហក ឬក៏ខកខានក្នុងព្រះបន្ទូលសន្យារបស់ព្រះអង្គណាមួយនោះឡើយ។ ព្រះយេស៊ូ ព្រះអង្គនៅតែដដែល ម្សិលមិញ ថ្ងៃនេះ និងរហូតអស់កល្បជានិច្ច។ ពីព្រោះព្រះអង្គមិនប្រែប្រួល កូនសូមថ្វាយការថប់បារម្ភទាំងឡាយរបស់កូនទៅកាន់ព្រះអង្គ និងទុកចិត្តថាជីវិតរបស់កូនស្ថិតនៅក្នុងផែនការដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ។ កូនសូមប្រែចិត្តចេញពីភាពសង្ស័យដែលកូនមាន និងទូលសូមទៅកាន់ព្រះអង្គថា ព្រះអង្គនឹងធ្វើឲ្យសេចក្តីជំនឿរបស់កូនលូតលាស់ឡើង និងកាន់តែទុកចិត្តលើព្រះអង្គថែមទៀត។ កូនសូមអរព្រះគុណព្រះអង្គសម្រាប់សេចក្តីស្មោះត្រង់ដែលមិនប្រែប្រួលរបស់ព្រះអង្គ។ កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។

ថ្ងៃទី៣

# ព្រះជាម្ចាស់

## សោយរាជ្យជាអធិបតេយ្យភាព

យ៉ូប ៤២:២

**“ទូលបង្គំទទួលស្គាល់ថាព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់បានហើយគ្មានការអ្វីមួយដែលធ្វើអោយព្រះអង្គទាល់ព្រះតម្រិះឡើយ។”**

អានបន្ថែម:  លោកុប្បត្តិ៥០:១៩–២០; ដានីញ៉ែល ៤:៣៤–៣៥; កិច្ចការ ៨:២៨

ប្រសិនបើលោកអ្នកជាឪពុកម្ដាយ លោកអ្នកច្បាស់ជាធ្លាប់និយាយទៅកាន់កូនៗរបស់លោកអ្នក អោយនៅឆ្ងាយពីចង្ក្រានហ្គាស ឬកំភ្លើង។ ប្រសិនកូនរបស់លោកអ្នកចង់ដឹងពីមូលហេតុនេះ ពួកគេច្បាស់ជាសួរលោកអ្នកថា ហេតុអ្វី? លោកអ្នកព្យាយាមពន្យល់ពួកគេ ប៉ុន្តែពួកគេនឹងមិនយល់ពីហេតុផលនេះឡើយ។ នៅទីបំផុត លោកអ្នកនឹងសម្រេចចិត្តនិយាយថា ពីព្រោះនេះជាអ្វីដែលប៉ាម៉ាក់" ។"និយាយដូច្នេះ

ព្រះគម្ពីរយ៉ូបគឺជារឿងរ៉ាវនៃការល្បងលបុរសសុចរិតម្នាក់ដ ើម្បីដោះស្រាយជាមួយនឹងការរងទុក្ខលំបាកដ៏ខ្លាំងក្លាដែលមើលទៅហាក់ដូចជាឥតន័យ។ ជាចុងបញ្ចប់ នៅក្នុងជំពូកទី៣៨ ព្រះជាម្ចាស់បានលេចមក និងមានព្រះបន្ទូលទៅកាន់យ៉ូប។ ព្រះអង្គមិនបានមានបន្ទូលនូវពាក្យដែលធ្វើឲ្យយ៉ូបបានទទួលការកម្សាន្តចិត្ត ឬជាចម្លើយទៅកាន់សំណួររបស់យ៉ូប ដូចដែលយើងប្រមើស្រមៃនោះឡើយ។ ប៉ុន្តែយ៉ូបបានទទួលចម្លើយដែលដូចនឹងអ្វីដែលឪពុកម្ដាយនិយាយទៅកាន់កូនរបស់ខ្លួន ពីព្រោះ" យ ើងបាននិយាយដូច្នេះហ "ើយព្រះជាម្ចាស់មានបន្ទូលថា តើអ្នកនៅឯណា ពេលដែលយើងបានបង្កើតផែនដីនេះ?

យ៉ូបបានបន្ទាបខ្លួន និងទទួលស្គាល់ថាព្រះជាម្ចាស់សោយរាជ្យជាអធិបតិយ្យភាព ហើយប្រកាសថាព្រះអង្គអាចធ្វើគ្រប់ការទាំងអស់ នោះហើយជាគោលបំណងរបស់ព្រះអង្គដែលគ្មានអ្វីអាចរារាំងព្រះអង្គបានឡើយ។ គាត់បានយល់ហើយថាព្រះជាម្ចាស់គឺជាស្ដេចសោយរាជ្យលើអ្វីៗទាំងអស់នៃរបស់ដែលបានបង្កើតមក។យ៉ូបបាននិយាយទៀតថា :នៅក្នុងយ៉ូប៤២)២៣-)“«ទូលបង្គំទទួលស្គាល់ថា ព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់បាន ហើយគ្មានការអ្វីមួយដែលធ្វើឲ្យព្រះអង្គ ទាល់ព្រះតម្រិះឡើយ។ ព្រះអង្គមានព្រះបន្ទូលមកទូលបង្គំថា “ម្ដេចក៏អ្នកសង្ស័យលើគម្រោងការរបស់យើង ដោយពោលពាក្យឥតខ្លឹមសារដូច្នេះ?” ពិតមែនហើយ ទូលបង្គំបានថ្លែងនូវសេចក្ដី ដ៏អស្ចារ្យដោយពុំដឹងខ្លួន គឺការអស្ចារ្យខ្ពស់លើសពីប្រាជ្ញា ដែលទូលបង្គំអាចយល់ និងអាចស្គាល់។” នៅក្នុងការសោយរាជ្យជាអធិបតិយ្យភាពរបស់ព្រះអង្គ យ៉ូបបានជួបការសាកល្បងដើម្បីនឹងបន្សុទ្ធសេចក្ដីជំនឿរបស់គាត់ និងបង្កើតការអត់ធ្មត់នៅក្នុងចរិតលក្ខណៈរបស់គាត់។ តាមរយៈទុក្ខវេទនាទាំងនេះ ព្រះជាម្ចាស់នៅតែមានសេចក្ដីមេត្តាករុណា ប្រណីសន្ដោស និងគ្រប់គ្រងដោយព្រះអង្គជានិច្ច។ ក្រោយពីបានស្វែងរកការកម្សាន្តចិត្តនិងចម្លើយអស់៤២ជំពូកមក យ៉ូបបានរកឃើញប្រភពដែលអាចជួយសម្រាលទុក្ខនេះ មិនមែនដោយសារការទទួលបានចម្លើយពីសំណួររបស់គាត់ ប៉ុន្តែជាការប្រែចិត្តចេញពីភាពសង្ស័យ ហើយត្រឡប់ទៅរកការទុកចិត្តលើព្រះជាម្ចាស់វិញ។

ការទុកចិត្តលើការសោយរាជ្យជាអធិបតិយ្យភាពរបស់ព្រះអម្ចាស់ គឺវាងាយស្រួលជាជាងធ្វើឲ្យការនោះសម្រេចដោយខ្លួនយើងជាពិសេសពេល យើងកំពុងទទួលបទពិសោធក្នុងទុក្ខវេទនា និងភាពឈឺចាប់របស់យើងផ្ទាល់។ តើយើងអាចទុកចិត្តដោយរបៀបណាថា ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់យ៉ាងខ្លាំងចំពោះយើង ក្នុងស្ថានភាពដែលពោរពេញដោយទុក្ខលំបាកដែលយើងកំពុងជួបប្រទះ? យើងអាចក្រឡេកមើលទៅព្រះយេស៊ូ ព្រះអង្គគ្មានបាបសោះ ប៉ុន្តែទ្រង់ជាអ្នកដែលរងទុក្ខវេទនា និងសុគតដើម្បីនឹងសង្គ្រោះយើង។ នៅក្នុងស្ថានភាពដែលពោរពេញដោយទុក្ខលំបាកដ៏សែនឈឺចាប់ និងខ្លោចផ្សា ក្នុងពេលដែលផ្លូវព្រះជាម្ចាស់ហាក់ដូចជាគ្មានទំនងសម្រាប់យើង សូមយើងអាចក្រឡេកមើលទៅកាន់ឈើឆ្កាង និងទទួលយកការកម្សាន្តចិត្ត ពីព្រះជាម្ចាស់ដែលសោយរាជ្យជាអធិបតិយ្យភាពរបស់យើង ព្រោះព្រះអង្គបានឃើញពីទុក្ខលំបាករបស់យើង ហើយបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយមកសុគតជំនួសយើង ដើម្បីឲ្យយើងបានទទួលការសង្គ្រោះ។

**ពីព្រោះព្រះជាម្ចាស់ជាព្រះដែលសោយរាជ្យជាអធិបតិយ្យភាព ហេតុនេះយើងមានការកម្សាន្តចិត្ត ពេលដែលយើងស្ថិតនៅក្នុងទុក្ខលំបាក។**

កំណត់សម្គាល់

ការឆ្លុះបញ្ចាំង

តើការល្បួងលអ្វីខ្លះ ដែលបច្ចុប្បន្នលោកអ្នកកំពុងជួបប្រទះ? តើការជឿជាក់លើការសោយរាជ្យជាអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ នាំឲ្យលោកអ្នកទទួលបានការកម្សាន្តចិត្តដោយរបៀបណា?

## សេចក្តីអធិស្ឋាន

តើការមើលទៅកាន់ឈើឆ្កាងដោយរបៀបណា ដែលធានាអះអាងថាព្រះជាម្ចាស់តែងតែយកព្រះហឫទ័យទុកដាក់ចំពោះលោកអ្នក?

*“ទូលបង្គំទទួលស្គាល់ថាព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់បានហើយគ្មានការអ្វីមួយដែលធ្វើអោយព្រះអង្គទាល់ព្រះតម្រិះឡើយ។”*

យ៉ូប ៤២:២

ព្រះបិតាដែលគង់នៅស្ថានសួគ៌ ព្រះអង្គជាព្រះអម្ចាស់លើអស់ទាំងអម្ចាស់ និងជាស្តេចលើអស់ទាំងស្តេច ហើយសោយរាជ្យលើអ្វីៗទាំងអស់នៅលើសកលលោកទាំងមូល។ ព្រះរាជ្យរបស់ព្រះអង្គគ្មានដែនកំណត់ និងគង់នៅអស់កល្បជានិច្ច។ គ្មានសត្រូវណាមួយ អាចធ្វើឲ្យផែនការរបស់ព្រះអង្គ ត្រូវវិនាសបាននោះឡើយ។ នៅក្នុងការសោយរាជ្យជាអធិបតិយ្យភាពរបស់ព្រះអង្គ ព្រះអង្គបានបន្ទាបអង្គទ្រង់ ដោយសុគតលើឈើឆ្កាង ដើម្បីឲ្យកូនបានទទួលការកម្សាន្តចិត្ត និងស្គាល់ពីភាពអស្ចារ្យរបស់ព្រះអង្គ។ ព្រះបិតា សូមបង្រៀនអោយកូនចេះបន្ទាបខ្លួនកូន នៅចំពោះព្រះអង្គ។ កូនសូមប្រគល់ការគ្រប់គ្រងលើជីវិតរបស់កូន ហើយសុំឱ្យព្រះអង្គផ្តល់ឲ្យកូននូវសន្តិភាពរបស់ទ្រង់។

កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។

ថ្ងៃទី៤

# ព្រះជាម្ចាស់យុត្តិធម៌

ទុតិយកថា ៣២:៤
“ព្រះអង្គជាថ្មដាហើយស្នាព្រះហស្តរបស់ព្រះអង្គល្អឥតខ្ចោះ។មាគ៌ារបស់ព្រះអង្គសុទ្ធតែទៀងត្រង់។ព្រះអង្គជាព្រះដ៏ស្មោះត្រង់ព្រះអង្គមិនអយុត្តិធម៌ឡើយដ្បិតព្រះអង្គសុចរិត និងយុត្តិធម៌។”

អានបន្ថែម: លោកុប្បត្តិ១៨:២៥; រ៉ូម៣:២៦; វិវរណៈ១៥:៣

មឹកមីមិក ត្រូវបានគេរកឃើញដំបូងនៅឆ្នេរសមុទ្រឥណ្ឌូណេស៊ីក្នុងឆ្នាំ១៩៩៨ គឺជាមេនៃការក្លែងបន្លំ។ សត្វសមុទ្រដែលមានល្បិចកលនេះអាចផ្លាស់ប្តូររូបរាង ពណ៌ និងចលនារបស់វាដើម្បីក្លែងបន្លំរូបរាងផ្សេងៗគ្នារហូតដល់ដប់ប្រាំ។ នៅក្នុងការសិក្សាព្រះបន្ទូល និងអធិស្ឋានថ្ងៃនេះ យើងចាប់ផ្តើមក្រឡេកមើលគុណលក្ខណៈនៃភាពល្អរបស់ព្រះជាម្ចាស់។ ទាំងនេះគឺជាគុណលក្ខណៈរបស់ព្រះអង្គ ក្នុងនាមយើងជាប្រជាជនរបស់ទ្រង់ យើងត្រូវបានត្រាស់ហៅឲ្យត្រាប់តាមរបៀបព្រះជាម្ចាស់។ ប៉ុន្តែមិនមែនដូចជាសត្វមឹកមីមិក ដែលធ្វើត្រាប់តាមតែជម្រៅស្បែកនោះទេ តែការធ្វើត្រាប់តាមរបស់យើងត្រូវតែចាប់ផ្តើមនៅក្នុងដួងចិត្ត។

ព្រះដ៏គួរឲ្យស្ញប់ស្ញែងរបស់យើងគឺសុចរិត មានន័យថាព្រះអង្គត្រឹមត្រូវក្នុងគ្រប់ការដែលទ្រង់ធ្វើ និងជាខ្នាតគំរូនៃអ្វីដែលត្រូវចាត់ទុកថាត្រឹមត្រូវនិងល្អ។ ក្នុងនាមជាព្រះដ៏ល្អ ព្រះអង្គរក្សាយើងឲ្យមានខ្នាតគំរូដូចគ្នា ដោយដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តការអាក្រក់ និងផ្តល់រង្វាន់ដល់អ្នកដែលប្រព្រឹត្តការល្អ។ នៅពេលលោកអ្នកគិតអំពីសេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់ លោកអ្នកប្រហែលជាគិតពីការដាក់ទណ្ឌកម្មរបស់ព្រះអង្គចំពោះមនុស្សអាក្រក់ ដូចជាការបំផ្លាញក្រុងសូដុំមក្នុងលោកុប្បត្តិ១៩ ។ ប៉ុន្តែយើងគួរតែគិតពីការការពាររបស់ព្រះជាម្ចាស់ចំពោះស្ត្រីមេម៉ាយ និងក្មេងកំព្រាផងដែរ។ ដោយសារព្រះអង្គជាព្រះដ៏យុត្តិធម៌ ព្រះអង្គគាំទ្រមនុស្សសុចរិតហើយព្រះអង្គជាអ្នកការពារដល់អស់អ្នកដែលធ្វើត្រូវបានរងអំពើអយុត្តិធម៌ផងដែរ។ ព្រះអង្គជាចៅក្រមដ៏ល្អ យុត្តិធម៌ក្នុងគ្រប់ការប្រព្រឹត្តទាំងអស់ ជាអ្នកការពារដល់អស់អ្នកដែលគ្មានការការពារ និងជារង្វាន់ដល់មនុស្សសុចរិត។
ការទុកចិត្តលើភាពយុត្តិធម៌របស់ព្រះជាម្ចាស់អាចជាការពិបាកសម្រាប់ពិភពលោកដែលពោរពេញទៅដោយភាពអយុត្តិធម៌។ បើព្រះជាម្ចាស់យុត្តិធម៌ ហេតុអ្វីបានជាមនុស្សអាក្រក់រីកចម្រើន? ហេតុអ្វីបានជាមនុស្សសុចរិតរងទុក្ខលំបាក? ហេតុអ្វីភាពអយុត្តិធម៌ហាក់ដូចជាមានប្រៀបលើភាពអយុត្តិធម៌? ប៉ុន្តែនៅពេលសំណួរទាំងនេះញាំញីយើង យើងអាចសម្លឹងមើលទៅព្រះយេស៊ូ។ ព្រះអង្គជាមនុស្សសុចរិតឥតខ្ចោះដែលបានរងទុក្ខដោយអយុត្តិធម៌ដើម្បីឲ្យយើងបានរាប់ជាសុចរិត ឬត្រូវបានរាប់ជាសុចរិតនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់។

នៅទីនេះនិងឥឡូវនេះ ជាញឹកញាប់យុត្តិធម៌នឹងមិនពេញលេញទេ។ ប៉ុន្តែរឿងនោះនឹងមិនតែងតែកើតឡើងនោះទេ។ នៅពេលដែលព្រះយេស៊ូយាងត្រឡប់មកវិញ និងនាំយកនូវភាពពេញលេញនៃនគររបស់ព្រះអង្គនោះរាល់ការខុសឆ្គងទាំងអស់នឹងត្រូវបានធ្វើឲ្យត្រឹមត្រូវ។ រហូតមកដល់ពេលនេះ យើងត្រូវបានត្រាស់ហៅឲ្យឈរលើអ្វីដែលត្រឹមត្រូវ យុត្តិធម៌ក្នុងការប្រព្រឹត្តទាំងអស់របស់យើង និងការពារអស់អ្នកដែលរស់នៅក្នុងសហគមន៍របស់យើងដែលរងភាពអយុត្តិធម៌។

ពីព្រោះព្រះជាម្ចាស់យុត្តិធម៌ ព្រះអង្គរំពឹងថាយើង និងក្លាយជាមនុស្សយុត្តិធម៌នៅក្នុងគ្រប់ការទាំងអស់នៃទំនាក់ទំនងរបស់យើង។

កំណត់សម្គាល់

ការឆ្លុះបញ្ចាំង

ហេតុអ្វីបានជាចាំបាច់សម្រាប់ព្រះដ៏ល្អដែលមានភាពយុត្តិធម៌? តើគុណលក្ខណៈនៃព្រះជាម្ចាស់នេះជួយលោកអ្នកឲ្យយល់ពីអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់លោកអ្នកនៅលើឈើឆ្កាងបានយ៉ាងដូចម្តេច?

តើវាមានន័យដូចម្ដេច សម្រាប់លោកអ្នកក្នុងការមានភាពយុត្តិធម៌ ក្នុងគ្រប់ទំនាក់ទំនងទាំងអស់របស់លោកអ្នក?

## សេចក្ដីអធិស្ឋាន

*“ព្រះអង្គជាថ្មដាហើយស្នាព្រះហស្តរបស់ព្រះអង្គល្អឥតខ្ចោះ។មាគ៌ារបស់ព្រះអង្គសុទ្ធតែទៀងត្រង់។ ព្រះអង្គជាព្រះដ៏ស្មោះត្រង់ព្រះអង្គមិនអយុត្តិធម៌ឡើយដ្បិតព្រះអង្គសុចរិត និងយុត្តិធម៌។”*

ទុតិយកថា ៣២:៤

ព្រះយេស៊ូវ, ព្រះអង្គគឺជាស្ដេចតែមួយគត់ដែលប្រកបដោយយុត្តិធម៌ និងព្រះប្រាជ្ញាញាណ។ កូនសម្លឹងមើលទៅផ្លូវរបស់ព្រះអង្គ ដើម្បីយល់ពីសេចក្ដីសុចរិតនិងភាពល្អរបស់ទ្រង់។ ទោះបីកូនជាមនុស្សបែកបាក់ រស់នៅក្នុងលោកិយ៍ដែលបែកបាក់នេះក៏ដោយ ព្រះអង្គនូវតែអាចរកយុត្តិធម៌បាននៅកន្លែងដែលគ្មានយុត្តិធម៌។ ព្រះអង្គបានត្រាស់ហៅកូនឲ្យធ្វើជាព្រះហស្ត និងព្រះបាទារបស់ព្រះអង្គ ដើម្បីនិយាយពីសេចក្ដីពិតការពារអស់អ្នកដែលគ្មានទីពឹង និងឈរនៅអ្វីដែលត្រឹមត្រូវ។ ឱព្រះ អម្ចាស់អើយ សូមបើកភ្នែកឲ្យកូនឃើញពីសេចក្ដីត្រូវការរបស់អ្នកដែលត្រូវការការព្យាបាលរបស់ព្រះអង្គផង។ សូមណែនាំផ្លូវកូន ដើម្បីឲ្យកូនធ្វើជាអ្នករក្សា



យុត្តិធម៌នៅលើលោកិយ៍នេះ។ កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។

ថ្ងៃទី ៥

# ព្រះជាម្ចាស់

## មានព្រះហឫទ័យអត់ធ្មត់

២ពេត្រុស ៣:៩

*ព្រះអម្ចាស់នឹងយាងមក តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ឥតបង្អែបង្អង់ ដូចអ្នកខ្លះនឹកស្មាននោះឡើយ។ ព្រះអង្គសំដែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះទ្រង់មិនសព្វព្រះហឫទ័យអោយនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យអោយមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិតវិញ។*

Additional Reading: Exodus 34:5–9; Psalm 86:15; Joel 2:12–13; Romans 5:8

នៅពេលដែលយើងគិតពីពាក្យថា“ អត់ធ្មត់ជាយូរ” ជាធម្មតាយើងងាយប្រើវាទៅនឹងពាក្យ“ អត់ធ្មត់” ។ យើងគិតថាការអត់ធ្មត់របស់ព្រះជាម្ចាស់ គឺដូចជាការអត់ធ្មត់របស់យើង ហើយថាព្រះអង្គកំពុងរង់ចាំដោយធម្មតា ។ ប៉ុន្តែការអត់ធ្មត់ជាយូរនេះមានន័យច្រើនជាងការអត់ធ្មត់។ វាមានន័យថា ព្រះជាម្ចាស់យឺតនឹងខ្ញាល់។ នៅផ្នែកម្ខាងទៀតនៃការអត់ធ្មត់របស់ព្រះអង្គគឺសេចក្តីក្រោធ។

ពេញមួយព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ ប្រជាជនអ៊ីស្រាអែលរាប់ឡើងវិញម្តងហើយម្តងទៀតថា ព្រះអម្ចាស់យឺតនឹងខ្ញាល់ ហើយមានសេចក្តីស្រឡាញ់ជារៀងរហូត។ ពួកគេបានទទួលស្គាល់ពីរបៀបបាបបានកប់នៅក្នុងដួងចិត្តមនុស្ស ប៉ុន្តែព្រះជាម្ចាស់នៅតែមានព្រះហឫទ័យអត់ធ្មត់ ដោយសេចក្តីល្អ និងសេចក្តីស្រឡាញ់របស់ទ្រង់។ ជនជាតិអ៊ីស្រាអែលនូវតែមានភាពឡើងចុះ ចំពោះការគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងការឃ្លាតឆ្ងាយពីព្រះអង្គ។ ពួកគេបានឃើញដោយផ្ទាល់ថា ព្រះជាម្ចាស់យឺតនឹងខ្ញាល់។ ជាធម្មតាភាពអត់ធ្មត់យូររបស់ព្រះអង្គ មិនស្ថិតស្ថេរជារៀងរហូតនោះទេ ប៉ុន្តែព្រះអង្គនៅតែមានព្រះហឫទ័យអត់ធ្មត់ខ្លាំង ជាងអ្វីដែលយើងគិត។

យើងសិក្សាព្រះគម្ពីរ២ពេត្រុស ជំពូក៣ ដែលសេចក្តីសន្យានៃការវិនិច្ឆ័យ និងការប្រោសលោះរបស់ព្រះជាម្ចាស់ប្រាកដជាបានសម្រេចមែន។ សូម្បីតែនៅក្នុងសេចក្តីសន្យានេះក៏ដោយ ក៏ព្រះអង្គមិនមានបំណងចង់ឲ្យមនុស្សណាម្នាក់ទទួលទោសដោយសេចក្តីក្រោធរបស់ព្រះអង្គដែរ។ ព្រះជាម្ចាស់យុត្តិធម៌ ហើយក្នុងពេលតែមួយព្រះអង្គមានព្រះហឫទ័យមេត្តាករុណាផងដែរ ។ ក្នុងនាមយើងជាអ្នកជឿលើព្រះអង្គ យើងបានទទួលការធានារ៉ាប់រងដោយការល្អដែលយើងមិនសមនឹងទទួលពីព្រះជាម្ចាស់ ជាការដែលនាំយើងឆ្ពោះទៅរកការសង្គ្រោះ និងតាមរយៈការផ្លាស់ប្រែជីវិត។ ព្រះអង្គប្រទានការសន្យាមកកាន់យើងថា ព្រះអង្គនឹងប្រទានផ្ទៃមេឃថ្មី និងផែនដីថ្មី។

ក្នុងនាមយើងជាអ្នកជឿ យើងមិនគួរភ្លេចថា កាលយើងនៅជាប់ជាមនុស្សមានបាបនៅឡើយ ព្រះគ្រីស្ទបានសុគតជំនួសយើង (រ៉ូម ៥: ៨)។ ព្រះអង្គបានរងទុក្ខលំបាកជាយូរមកហើយដើម្បីជាប្រយោជន៍ដល់យើង ហើយព្រះអង្គបន្តអត់ធ្មត់ចំពោះអ្នកមិនជឿ។ ពេលមនុស្សណាម្នាក់មិនទាន់ស្គាល់ព្រះគ្រីស្ទ ពួកគេនៅតែជាប់ក្នុងអំពើបាបរបស់ពួកគេដដែល។ យើងទាំងអស់គ្នាត្រូវបានត្រាស់ហៅឲ្យនាំយកសេចក្តីសង្ឃឹមនៃដំណឹងល្អនេះទៅពួកគេ។ ការប្រែចិត្ត និងការអត់ទោសបាបគឺជាអំណោយសម្រាប់មនុស្សគ្រប់គ្នានៅលើពិភពលោកនេះ មិនថាពួកគេស្ថិតនៅក្នុងអតីតកាល ឬ

បច្ចុប្បន្នរបស់ពួកគេបែបណានោះឡើយ។ ការសង្គ្រោះមិនស្ថិតនៅលើយើងនោះឡើយ ប៉ុន្តែនេះជាឯកសិទ្ធិសម្រាប់យើង ក្នុងការចែកចាយសេចក្តីពិតនៃសេចក្តីសង្ឃឹមរបស់ព្រះជាម្ចាស់ដល់ពួកគេ។

នៅពេលយើងយល់ពីអត្ថន័យនៃព្រះហឫទ័យអត់ធ្មត់របស់ព្រះជាម្ចាស់ ការនោះនឹងផ្លាស់ប្តូររបៀបដែលយើងចូលទៅរកអ្នកមិនមែនជាគ្រិស្តបរិស័ទ។ យើងរៀនអត់ធ្មត់ក្នុងទំនាក់ទំនងទាំងនោះ ក៏ព្រោះយើងជាអ្នកចែកចាយសេចក្តីជំនឿនិងសេចក្តីស្រឡាញ់របស់យើងដោយសប្បុរស។

ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យអត់ធ្មត់ យើងក៏អាចអត់ធ្មត់ក្នុងការចែកចាយដំណឹងល្អនៃសេចក្តីមេត្តាករុណា និងព្រះគុណរបស់ព្រះជាម្ចាស់បានផងដែរ។

កំណត់សម្គាល់

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

ការឆ្លុះបញ្ចាំង

តើព្រះជាម្ចាស់មានព្រះទ័យអត់ធ្មត់ចំពោះរឿងជាក់លាក់អ្វីខ្លះក្នុងជីវិតរបស់លោកអ្នក? តើលោកអ្នកបានឆ្លើយតបយ៉ាងដូចម្តេច?

________________________________________

________________________________________

________________________________________

________________________________________



## សេចក្តីអធិស្ឋាន

ដល់ទំនាក់ទំនងរបស់អ្នក?

ព្រះអម្ចាស់នឹងយាងមក តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ឥតបង្អែបង្អង់ ដូចអ្នកខ្លះនឹកស្មាននោះឡើយ។ ព្រះអង្គសំដែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះទ្រង់មិនសព្វព្រះហឫទ័យអោយនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យអោយមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិតវិញ។

២ ពេត្រុស ៣:៩

ព្រះជាម្ចាស់របស់កូន ព្រះអង្គបានបង្ហាញព្រះហឫទ័យអត់ធ្មត់របស់ព្រះអង្គ នៅក្នុងព្រះបន្ទូលរបស់ទ្រង់ និងនៅក្នុងជីវិតរបស់កូន។ គ្មានអ្នកណាអាចបង្ហាញសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ដែលមិនប្រែប្រួលដូចព្រះអង្គបានឡើយ។ គំរូនៃព្រះហឫទ័យអត់ធ្មត់របស់ព្រះអង្គត្រូវបានបង្ហាញនៅលើឈើឆ្កាង ជាកន្លែងដែលព្រះអង្គបានសុគតសម្រាប់អំពើបាបរបស់មនុស្សគ្រប់ៗគ្នា សូ

ម្បីតែអ្នកដែលមិនព្រមទទួលព្រះអង្គ។ សូម្បីតែនៅពេលខ្ញុំស្ថិតនៅក្នុងអំបើបាប ព្រះអង្គផ្តល់ព្រះគុណដល់កូនដើម្បីប្រែចិត្ត ក៏ព្រោះតែព្រះអង្គជាព្រះបិតាដ៏ល្អ។ កូនសូមឲ្យព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបំពេញកូនដោយអំណោយទាននៃការអត់ធ្មត់ ដើម្បីបង្ហាញការអត់ធ្មត់នេះ ដល់អ្នកដទៃតាមរបៀបដែលព្រះអង្គបានអត់ធ្មត់នឹងកូនដែរ។ កូនសូមអធិស្ឋាន នៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។

ថ្ងៃទី ៦

# ព្រះជាម្ចាស់

## មានព្រះហឫទ័យសប្បុរស

អេភេសូ២:៧

*. . . ព្រះអង្គបង្ហាញព្រះហឫទ័យសប្បុរសចំពោះយើង ក្នុងអង្គព្រះគ្រិស្តយេស៊ូដូច្នេះ ដើម្បីបង្ហាញអោយមនុស្សគ្រប់ជំនាន់ខាងមុខ ស្គាល់ព្រះគុណដ៏ប្រសើរលើសលប់បំផុតរបស់ព្រះអង្គ*

អានបន្ថែម: ទុតិយកថា ៧:៧–៨; លូកា ៦:៣៥; ទីតុស ៣:៤–៥
(ជម្រើសបន្ថែម): ១ កូរិនថូស ១៣:៤; រ៉ូម ២:៤)

នៅក្នុងកម្រងភាពយន្ត The Lord of Rings, មានចរិតលក្ខណៈជាច្រើន បង្ហាញឡើង សម្រាប់ភាពអាត្មានិយមរបស់ពួកគេ។ ប៉ុន្តែគ្មាននរណាម្នាក់ដូចនឹង Samwise Gamgee ដែលជា Hobbit ដែលមានបន្ទាបខ្លួន និងស្មោះត្រង់ក្នុងការដើរតាម Frodo ទៅក្នុងគ្រោះថ្នាក់ និងការស្លាប់ដ៏ជាក់លាក់ ដើម្បីជួយមិត្តភក្តិរបស់គាត់ដែលទទួលបន្ទុកដ៏ធ្ងន់នៃនាំយកចិញ្ចៀនមួយ និងធ្វើឲ្យសម្រេចតាមបេសកកម្មរបស់គាត់ក្នុងការបំផ្លាញវា។ នៅពេលពួកគេជិតដល់ចុងបញ្ចប់នៃដំណើររបស់ពួកគេ Samwise ទៅដោយគ្មានទឹក ដើម្បីឲ្យលោកFrodo មានគ្រប់គ្រាន់។ ហើយដូច Samwise គេងមិនលក់នៅយប់មួយ គាត់និយាយទៅកាន់ខ្លួនឯងថា" ខ្ញុំនឹងទៅដល់ទីនោះ ទោះបីជាខ្ញុំត្រូវលោះបង់អ្វីៗទាំងអស់ចោលសូម្បីតែឆ្អឹងរបស់ខ្ញុំក៏ដោយ។ ហើយខ្ញុំនឹងលើកលោក Frodo ឡើងឡើងដោយខ្លួនឯង ទោះបីជាត្រូវលះបង់ជីវិតរបស់ខ្ញុំក៏ដោយ។ ហើយនោះជាការដ៏វិសេសវិសាល ដែលលោក Samwiseបានធ្វើ ដោយដឹកលោក Frodo នៅពេលដែលគាត់មិនមានកម្លាំងដើរទៀត។ លោកSamwise គឺជាលក្ខណមិត្តដ៏សប្បុរស និងមិនគិតពីខ្លួនឯង។

ដូចគ្នានឹងទំនាក់ទំនងដែលព្រះជាម្ចាស់ មានសម្រាប់យើងផងដែរ។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើងគឺសប្បុរស។ នៅពេលយើងនិយាយអំពីព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ យើងចង់សំដៅទៅលើការយកចិត្តទុកដាក់ដ៏សប្បុរសរបស់ព្រះអង្គចំពោះអស់អ្នកដែលព្រះអង្គស្រឡាញ់។ អ្វីដែលអស្ចារ្យចំពោះព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់គឺថា យើងបានទទួលដោយមិនបង់ថ្លៃ យើងមិនបានស្វែងរកហើយក៏សាកសមនឹងទទួលបាន។ តាមពិតព្រះគម្ពីរបង្រៀនយើងថា ព្រះជាម្ចាស់បង្ហាញសេចក្តីសប្បុរសដ៏ស្មោះដល់អស់អ្នកដែលមិនសមនឹងទទួល! ព្រះជាម្ចាស់បានដាក់ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គមកលើអ៊ីស្រ៉ាអែល ទោះបីពួកគេមិនមែនជាសាសន៍ដែលមានចំនួនច្រើនជាងសាសន៍នានាក៏ដោយ (ចោទិយកថា ៧:៧-៨)។ បន្ទាប់មកព្រះជាម្ចាស់បានដឹកនាំជនជាតិអ៊ីស្រ៉ាអែលដោយព្រះហឫទ័យសប្បុរស ទោះបីជាពួកគេមិនស្មោះត្រង់ក៏ដោយ (ហូសេ ១១:៤)។ ហើយដោយសារព្រះហឫទ័យសប្បុរសដ៏ស្មោះរបស់ទ្រង់កាលដែលយើងនៅជាមនុស្សមានបាបនៅឡើយ នោះព្រះអង្គបានសុគតសម្រាប់យើង(រ៉ូម ៥:៨)។ ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គបានលះបង់អង្គទ្រង់ មិនមែនសម្រាប់អ្វីដែលព្រះអង្គអាចទទួលបាននោះទេ ប៉ុន្តែសម្រាប់អ្វីដែលយើងអាចទទួលបាន។

ទោះជាយើងមានបាប និងមិនស្មោះត្រង់ក៏ដោយ ព្រះជាម្ចាស់បានចាត់ព្រះរាជបុត្រារបស់ព្រះអង្គតែមួយឲ្យសុគតសំរាប់យើង ដើម្បីផ្សះផ្សាយើងជាមួយព្រះអង្គ។ ដូច្នេះយើងអាចមានទំនាក់ទំនងជាមួយព្រះដ៏អស្ចារ្យនិងល្អនេះ។ យើងមិនបានធ្វើអ្វីដែលសមនឹងទទួលបានការនេះនោះទេ ប៉ុន្តែដោយសារព្រះហឫទ័យសប្បុរសដ៏លើសលប់របស់ព្រះអង្គ យើងបានក្លាយជាអ្នកទទួលព្រះគុណរបស់ទ្រង់។ ហើយសម្រាប់ភាពអស់កល្បជានិច្ច ភាពខ្ពង់ខ្ពស់នៃព្រះគុណរបស់ព្រះជាម្ចាស់ នឹងត្រូវបានបង្ហាញមកកាន់យើង ដើម្បីភ្ញាក់ផ្អើលនៅពេលយើងក្រេបយកព្រះគុណដ៏សប្បុរសរបស់ព្រះអង្គមកលើយើង។

**ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរស យើងមានព្រះពរដ៏នៅអស់កល្បជានិច្ច។**

កំណត់សម្គាល់

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

ការឆ្លុះបញ្ចាំង

រ៉ូម២:៤ ចែងថា" ព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ មានគោលបំណងជួយឲ្យអ្នកប្រែចិត្ត" ក្នុងអំឡុងពេលមួយសប្តាហ៍នេះ តើព្រះជាម្ចាស់បានបើកសម្តែងអ្វីនៅក្នុងជីវិតរបស់លោកអ្នក ដែលលោកអ្នកត្រូវប្រែចិត្ត? តើព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ ជួយលោកអ្នកឲ្យប្រែចិត្ត និងទុកចិត្តលើព្រះអង្គយ៉ាងដូចម្តេច?

_______________________________________________

_______________________________________________



*. . . ព្រះអង្គបង្ហាញព្រះហឫទ័យសប្បុរសចំពោះយើង ក្នុងអង្គព្រះគ្រិស្តយេស៊ូដូច្នេះ ដើម្បីបង្ហាញអោយមនុស្សគ្រប់ជំនាន់ខាងមុខ ស្គាល់ព្រះគុណដ៏ប្រសើរលើសលប់បំផុតរបស់ព្រះអង្គ*

អេភេសូ ២:៧

ឱព្រះអម្ចាស់អើយ ព្រះហឫទ័យសប្បុរសដ៏ស្មោះរបស់ព្រះអង្គបានទាក់ទាញចិត្តកូនឲ្យប្រែចិត្ត ហើយទទួលបានព្រះពររបស់ព្រះអង្គ។ កូនមិនបានធ្វើអ្វីដែលសមនឹងទទួលនូវព្រះហឫទ័យសប្បុរសរបស់ព្រះអង្គទេ។ ប៉ុន្តែនៅក្នុងព្រះគ្រីស្ទ ព្រះអង្គបានផ្តល់ឲ្យកូននូវអ្វីៗគ្រប់យ៉ាងដែលកូនត្រូវការដូចជាព្រះពរខាងវិញ្ញាណ ខាងរាងកាយ ខាងផ្លូវចិត្ត ខាងហិរញ្ញវត្ថុ និងអ្វីៗជាច្រើនទៀត។ ព្រះហឫទ័យសប្បុរសរបស់ទ្រង់នាំឲ្យដួងចិត្តកូនមានអំណរគ្រប់រដូវកាល។ សូមអរព្រះគុណចំពោះព្រះគុណដ៏អស់កល្បរបស់ព្រះអង្គ។ ដូចដែលព្រះអង្គបើកភ្នែកកូនចំពោះសេចក្តីសប្បុរសរបស់ទ្រង់នៅក្នុងជីវិតរបស់កូន សូមជួយកូនឲ្យបង្ហាញសេចក្តីសប្បុរសចំពោះអ្នកដទៃដែលនៅជុំវិញកូនផងដែរ។ កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត អាម៉ែន។

## សេចក្តីអធិស្ឋាន

EVERY NATION

Every Nation is a global family of churches and ministries that exists to honor God by establishing Christ-centered, Spirit-empowered, socially responsible churches and campus ministries in every nation.

EveryNation.org/Fasting

#ENFAST2021 #AWESOMEGOD2021